ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច

TRUST REGULATOR

លេខៈ ០២៦/២៣ ន.ប.ធ. /ស.ជ ណ.


# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជនដែលត្រូវចូលរួមការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ សម្រាប់ក្រុមហ៊ុនបរធនបាល, ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់មេត្តាជ្រាបថា÷ **ន.ប.ធ.** នឹងរៀបចំការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ **នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៩ : ៣០ នាទីព្រឹក ដល់ម៉ោង ១១ : ០០ នាទីព្រឹក នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៥។**

**សម្គាល់÷ ន.ប.ធ.** សូមរក្សាសិទ្ធក្នុងការកែប្រែការរៀបចំការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ ប្រសិនបើមានការចាំបាច់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបេក្ខជនដែលត្រូវចូលរួមការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ ទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២៣

**និយ័តករបរធនបាលកិច្ច**

**លេខទំនាក់ទំនង**

- កញ្ញា ស៊ុន វន្នី
- Tel : ០៧៧ ២៧៨ ០១៩ (Telegram)


អាសយដ្ឋាន : អគារ ១៦៨F (ជាន់ទី៨) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamres 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia

ទូរសព្ទ : (+៨៥៥)២៣-២៣៧-៨៨៨

សារអេឡិចត្រូនិច : info@trustregulator.gov.kh

គេហទំព័រ : www.trustregulator.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច

លេខ: ០៧.៣២៩/២៣ ន.ប.ធ./ស.ណ.ន.

ថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែ សីហា ឆ្នាំ២០២៣

# សេចក្តីណែនាំ
## ស្តីពី
## ការប្រឡងគុណវុឌ្ឍិដែលរៀបចំដោយនិយ័តករបរធនបាលកិច្ច
## សម័យប្រឡង ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣
## ចាប់ពីម៉ោង ៩ : ៣០ ដល់ ១១ : ០០ ព្រឹក
## ទីកន្លែង: អគារមជ្ឈមណ្ឌលអតិថិជនធុរកិច្ច ជាន់ទី១៥

ក្នុងគោលបំណងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យក្នុងការប្រឡងគុណវុឌ្ឍិ ដែលរៀបចំដោយ **ន.ប.ធ.** បេក្ខជនទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រឡងដូចខាងក្រោម÷

**១. វិន័យ**

**ក. បេក្ខជនត្រូវ÷**

- មកដល់មណ្ឌលប្រឡងឱ្យបាន ៣០ (សាមសិប) នាទីមុនការប្រឡងចាប់ផ្តើម
- បង្ហាញបណ្ណសម្គាល់ខ្លួនដូចជា÷ អត្តសញ្ញាណបណ្ណ សំបុត្រកំណើត លិខិតឆ្លងដែន បណ្ណបើកបរ ឬឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់ពីអត្តសញ្ញាណរបស់បេក្ខជនមុនពេលចូលក្នុងបន្ទប់ប្រឡង
- ស្លៀកពាក់ឱ្យបានសមរម្យ
- ស្នើសុំការអនុញ្ញាតពីគណៈកម្មការជាមុន ករណីមានការចាំបាច់ត្រូវចេញពីបន្ទប់ប្រឡងក្នុងអំឡុងពេលប្រឡង
- គោរពតាមការណែនាំរបស់គណៈកម្មការ។

**ខ. បេក្ខជនមិនត្រូវ÷**

- យកសំណៅឯកសារ និងកំណត់ត្រាផ្សេងៗ ឬសម្ភារៈដទៃទៀតដូចជា អាវុធជាតិផ្ទុះ កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកផ្សេងៗចូលបន្ទប់ ឬមណ្ឌលប្រឡងឡើយ **លើកលែងតែម៉ាស៊ីនគិតលេខ**
- ប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងផ្សេងៗ ឬឧបករណ៍សម្រាប់ទំនាក់ទំនងផ្សេងទៀតក្នុងពេលប្រឡង
- ចូលបន្ទប់ប្រឡងមុនពេលគណៈកម្មការហៅឈ្មោះឱ្យចូល
- ប្តូរសន្លឹកកិច្ចការ ឬក្រដាសព្រាងឱ្យគ្នាទៅវិញទៅមក ឬផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា ឬដាក់សន្លឹកកិច្ចការឆ្ងាយពីមុខរបស់ខ្លួនបង្កឱ្យអ្នកដទៃអាចមើល ឬឆក់យកបានឡើយ
- ធ្វើសញ្ញាសម្គាល់ណាមួយលើសន្លឹកកិច្ចការ

- ជជែក ឬពិភាក្សាគ្នាដែលធ្វើឱ្យរំខានអ្នកដទៃ
- ខ្ទីបិច ខ្ទៅដៃ ទឹកលុប ជ័រលុប ឬបន្ទាត់ពីអ្នកដទៃ
- ដើបឈរ ងាកឆ្វេង-ស្តាំ អើតឈ្ងោកទៅមុខ បែរទៅក្រោយ ឬដើរចេញពីកន្លែងអង្គុយដោយគ្មានការអនុញ្ញាតពីអនុរក្ស ក្នុងអំឡុងពេលប្រឡង
- ចេញក្រៅបន្ទប់ប្រឡងក្នុងអំឡុងពេល ៣០ (សាមសិប) នាទីដំបូង គិតចាប់ពីពេលចាប់ផ្តើមធ្វើវិញ្ញាសាសរសេរ លើកលែងតែមានការចាំបាច់ និងទទួលបានការអនុញ្ញាតពីអនុរក្ស
- សរសេរលើសន្លឹកកិច្ចការណាដែលគ្មានហត្ថលេខារបស់គណៈកម្មការ។

**គ. ករណីយឺតយ៉ាវ÷**

- តិចជាង ១៥ (ដប់ប្រាំ) នាទី÷ បេក្ខជនត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មការរៀបចំការប្រឡង
- លើសពី ១៥ (ដប់ប្រាំ) នាទី÷ បេក្ខជនត្រូវស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មការរៀបចំការប្រឡង។

**២. វិធានការ**

**ក. ត្រូវបានពិន្ទុសូន្យករណីបេក្ខជនប្រព្រឹត្តល្មើសដូចខាងក្រោម÷**

- ដើរចុះឡើងចេញពីតុប្រឡងដោយគ្មានការអនុញ្ញាតពីគណៈកម្មការរៀបចំការប្រឡង
- ហែកសន្លឹកកិច្ចការចោល ឬមិនប្រគល់សន្លឹកកិច្ចការជូនគណៈកម្មការរៀបចំការប្រឡង
- ផ្លាស់ប្តូរកន្លែងអង្គុយដោយពុំមានការអនុញ្ញាតជាមុនពីគណៈកម្មការរៀបចំការប្រឡង
- ឱ្យ ឬទទួលសន្លឹកកិច្ចការរបស់ខ្លួនទៅ ឬពីអ្នកដទៃចម្លង បន្ទាប់ពីទទួលការព្រមានពីអនុរក្សរួចមក ហើយ ឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន ឬជួយសរសេរលើសន្លឹកកិច្ចការរបស់អ្នកដទៃ
- ឱ្យអ្នកដទៃប្រឡងជំនួស
- ធ្វើសញ្ញាសម្គាល់ផ្សេងៗលើសន្លឹកកិច្ចការប្រឡង
- ដណ្តើមយកសន្លឹកកិច្ចការអ្នកដទៃមកចម្លង
- ហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ ឬយកសន្លឹកកិច្ចការអ្នកដទៃមកធ្វើជាសន្លឹកកិច្ចការរបស់ខ្លួន
- ប្រើប្រាស់ទូរសព្ទ វិទ្យុទាក់ទង កុំព្យូទ័រ ឬសារអេឡិចត្រូនិកគ្រប់ប្រភេទ ដែលប្រើប្រាស់សម្រាប់ទំនាក់ទំនងក្នុងការធ្វើវិញ្ញាសាសរសេរ
- បោះវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង ឬចេញទៅយកឯកសារ ឬក្លែងបន្លំឯកសារ ឬយកសំណៅចម្លើយពាក់ព័ន្ធនឹងវិញ្ញាសាចូលក្នុងបន្ទប់ប្រឡងក្នុងពេលកំពុងធ្វើវិញ្ញាសា។

**ខ. ហាមមិនឱ្យប្រឡង ឬត្រូវបានបញ្ឈប់ការប្រឡង និងចាត់ទុកជាមោឃៈចំពោះករណីដូចខាងក្រោម÷**

- ប្រើអំពើហិង្សា ឬបង្កជម្លោះនៅក្នុងបរិវេណនៃមណ្ឌលប្រឡង
- យកអាវុធជាតិផ្ទុះចូលក្នុងបន្ទប់ប្រឡង

__**សម្គាល់**__÷ ចំពោះកំហុសក្រៅពីករណីដែលបានចែងក្នុងវិធានការខាងលើ នឹងត្រូវបានកំណត់ដោយប្រធានគណៈកម្មការរៀបចំការប្រឡង តាមកំហុសជាក់ស្តែង។